**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**សូមគោរពជូន**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍ ស្ដីពីលទ្ធផលនៃកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង នៅស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ។

**យោង** ៖លិខិតលេខ០៥០ របក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ របស់ក្រសួងទេសចរណ៍។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន សម្ដេចតេជោ នាយករដ្ឋមន្ត្រី មេត្តាជ្រាបថា កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ នៅស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ គណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង បានរៀបចំកិច្ចប្រជុំពិភាក្សាលើការការពារ ការជំរុញការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ដោយមានការអញ្ជើញចូលរួម ពីសមាជិក សមាជិកានៃគណៈកម្មការនេះ និងតំណាងអង្គភាពពាក់ព័ន្ធមួយចំនួន សរុប ចំនួន ៤១នាក់។

អង្គប្រជុំបានពិភាក្សា និងសម្រេចបានលទ្ធផល ដូចខាងក្រោម៖

- ឯកភាពតាមសំណើរបស់ ឯកឧត្តម ស ថាវី អភិបាលនៃគណៈអភិបាលខេត្តឧត្ដរមានជ័យ ក្នុងការបង្កើតក្រុមការងារថ្នាក់ខេត្តមួយ ដើម្បីត្រួតពិនិត្យនិយាមការតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង
- ឯកភាពផ្ដល់ជូនលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការសិក្សាអំពីការអភិវឌ្ឍន៍តំបន់ "ក១"(កន្លែងដុតខ្មោច ប៉ុលពត), តំបន់ "ក៣" (ផ្ទះតាម៉ុក ផ្ទះកណ្ដាលលើភ្នំដងរែក), តំបន់ "ខ១" (កន្លែងដុតខ្មោច សុន សេន) និង តំបន់ "ខ៥" (ផ្ទះតាម៉ុក សារមន្ទីរតាម៉ុក) ដោយរៀបចំសាងសង់ជួសជុលតាមលំនាំដើម ដោយមានផែនការអភិវឌ្ឍន៍ច្បាស់លាស់ ដើម្បីលើកសំណើសុំការអនុញ្ញាតពីរាជរដ្ឋាភិបាល
- ឯកភាពជំរុញការរៀបចំតភ្ជាប់ផ្លូវទៅកាន់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រទាំង១៤ចំណុច ដែលមានចែងក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ស្ដីពីការកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង
- ចំពោះករណីការជីកដីយកមកធ្វើផ្លូវព័ទ្ធជុំវិញមាត់បឹងអន្លង់វែង គឺត្រូវមានការឯកភាពពីក្រសួងធនធានទឹក និងឧតុនិយម
- រៀបចំបោះបង្គោលតំបន់ប្រវត្តិសាស្ត្រអន្លង់វែងទាំង១៤ចំណុច ដោយមានដាក់ស្លាកឈ្មោះ ស្លាកសញ្ញាបង្ហាញទីតាំងច្បាស់លាស់
- ក្រសួងទេសចរណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលាខេត្តឧត្ដរមានជ័យ សហការរៀបចំបើកវគ្គបណ្ដុះបណ្ដាលមគ្គុទ្ទេសក៍ទេសចរណ៍ក្នុងតំបន់ ដោយប្រើប្រាស់ឯកសណ្ឋានមគ្គុទ្ទេសក៍ក្នុងតំបន់។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូមសម្ដេចតេជោនាយករដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ និងគោរពសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់។

*ដោយសេចក្ដីគោរពបំផុត*

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៥

**រដ្ឋមន្ត្រីស្ដីទី**

**ប៊ុន អ៊ុយ**